# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

# របាយការណ៍ស្តីពីលទ្ធផលការងារ

# ប្រចាំឆមាសទី១

# ឆ្នាំ ២០១៦

រៀបចំដោយ: លោក ហ៊ុយ វណ្ណា

អគ្គលេខាធិការ

# របាយការណ៍ស្តីពីលទ្ធផលការងារ
# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
# ប្រចាំឆមាសទី១ ឆ្នាំ២០១៦

## I. សេចក្តីផ្តើម

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានរៀបចំ **របាយការណ៍ស្តីពីលទ្ធផលការងារសមាគមប្រចាំឆមាសទី១ សម្រាប់ឆ្នាំ២០១៦** ក្នុងគោលបំណងដើម្បីបង្ហាញពីសកម្មភាព និងលទ្ធផលការងារដែលសមាគមសម្រេចបាន ជូនថ្នាក់ដឹកនាំ និងសមាជិក-សមាជិកា ជ្រាបជារបាយការណ៍។ របាយការណ៍ប្រចាំឆមាសទី១ គឺជាសកម្មភាព និងលទ្ធផលការងារដែលសម្រេចបាន ពីខែមករា ដល់ ខែមិថុនា ឆ្នាំ២០១៦។

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានបង្កើតឡើងដោយក្រុមហ៊ុនអ្នកវិនិយោគលើវិស័យអភិវឌ្ឍន៍លំនៅឋាន ហើយបានចុះបញ្ជីសមាគម និងអនុញ្ញាតជាផ្លូវការ ដោយក្រសួងមហាផ្ទៃ ដែលមានលិខិតលេខៈ ៩៨៥៧ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ចេញដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អាសយដ្ឋានសមាគមស្ថិតនៅអាគារលេខ ៨៥-៨៨ មហាវិថី គីមអ៊ីលស៊ុង សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

យោងលើស្មារតីអង្គប្រជុំបានសម្រេចលើមតិភាគច្រើន បានជ្រើសរើសសមាសភាពថ្នាក់ដឹកនាំ ១រូប គឺលោកឧកញ៉ា **លី ហួរ** ជាប្រធានសមាគម។

## II. រចនាសម្ព័ន្ធសមាគម

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ទទួលបានសមាជិក-សមាជិកាចំនួន ៣២ក្រុមហ៊ុន ដោយសមាសភាពថ្នាក់ដឹកនាំមាន ប្រធានសមាគម ១រូប អនុប្រធានសមាគម ១០រូប សមាជិក ២១រូប និងក្រុមអគ្គលេខាធិការដ្ឋានចំនួន ៧រូប។ សមាគមបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង គណៈកម្មាការទទួលបន្ទុកលើវិស័យនីមួយៗ លក្ខន្តិក បទបញ្ជាផ្ទៃក្នុង កំណត់ប្រាក់ភាគទានប្រចាំឆ្នាំ និងអត្ថប្រយោជន៍សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន ដែលបានចុះឈ្មោះជាសមាជិកសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា។

❖ **ប្រាក់ភាគទានប្រចាំឆ្នាំ មានដូចខាងក្រោម៖**

- ប្រធានសមាគម ចំនួន ១០,០០០ ដុល្លារអាមេរិក ក្នុង១ឆ្នាំ
- អនុប្រធានសមាគម ចំនួន ១០,០០០ ដុល្លារអាមេរិក ក្នុង១ឆ្នាំ
- សមាជិកសមាគម ចំនួន ៣,០០០ ដុល្លារអាមេរិក ក្នុង១ឆ្នាំ

❖ **សមាសភាពថ្នាក់ដឹកនាំសមាគម៖**

- ប្រធានសមាគម ០១ រូប
- អនុប្រធានសមាគម ១០ រូប
- ក្រុមអគ្គលេខាធិការដ្ឋាន ០៥ រូប
- ទីប្រឹក្សាសមាគម ០២ រូប


សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
រចនាសម្ព័ន្ធថ្នាក់ដឹកនាំ
សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
ឧកញ៉ា លី ហួរ
ប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន
អនុប្រធាន


អគ្គលេខាធិការដ្ឋាន
លោក ហ៊ុយ វណ្ណា
អគ្គលេខាធិការ
ទីប្រឹក្សាច្បាប់
ហេរញ្ញិក
លោក គីម ធារិទ្ធ
លេខាធិការ
ជំនួយការ
ទីប្រឹក្សាច្បាប់

1. **បញ្ជីរាយនាមថ្នាក់ដឹកនាំ សមាជិក-សមាជិកា និងក្រុមអគ្គលេខាធិការដ្ឋានសមាគម**

❖ **បញ្ជីរាយនាមថ្នាក់ដឹកនាំ និងសមាជិក-សមាជិកាសមាគម មាន ៣២រូបៈ**

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | លោកឧកញ៉ា លី ហួរ | ប្រធាន |
| ២ | អ្នកឧកញ៉ា ហុង ពីវ | អនុប្រធាន |
| ៣ | លោកឧកញ៉ា ថៃ ជាហួត | អនុប្រធាន |
| ៤ | លោកឧកញ៉ា លាង ម៉េង | អនុប្រធាន |
| ៥ | លោកឧកញ៉ា ជាម យុនណាត | អនុប្រធាន |
| ៦ | លោកឧកញ៉ា តេង ហឿង | អនុប្រធាន |
| ៧ | លោកជំទាវ ខា ឡេង | អនុប្រធាន |
| ៨ | លោកជំទាវឧកញ៉ា កែវ ម៉ាលី | អនុប្រធាន |
| ៩ | លោកឧកញ៉ា លី សេងឃាង | អនុប្រធាន |
| ១០ | លោកឧកញ៉ា លាង សាំង | អនុប្រធាន |
| ១១ | លោកឧកញ៉ា តាំង គួង | អនុប្រធាន |
| ១២ | លោកឧកញ៉ា ប៊ុន ហៃ | សមាជិក |
| ១៣ | លោកឧកញ៉ា ថៃ ឈុនគ្រី | សមាជិក |
| ១៤ | លោកឧកញ៉ា ព្រំ សុធី | សមាជិក |
| ១៥ | លោកឧកញ៉ា លីម ឈាងហាក់ | សមាជិក |
| ១៦ | លោកឧកញ៉ា គង់ ប៊ុនហាវ | សមាជិក |
| ១៧ | ឯកឧត្តម តុល លន | សមាជិក |
| ១៨ | ឯកឧត្តម មាស វណ្ណា | សមាជិក |
| ១៩ | លោកជំទាវ សែម សម្ផស្ស | សមាជិក |
| ២០ | លោកជំទាវ សេង រ៉ាវី | សមាជិក |
| ២១ | លោក ចាន់ សុង | សមាជិក |
| ២២ | លោក ទន់ ឆៃលីម | សមាជិក |
| ២៣ | លោក ព្រំ ខយ | សមាជិក |
| ២៤ | លោក ស្រេង ឈាងហោ | សមាជិក |
| ២៥ | លោក កៃ ចាន់ | សមាជិក |
| ២៦ | លោក ជា រី | សមាជិក |
| ២៧ | លោក អ៊ីវ ម៉េង | សមាជិក |
| ២៨ | លោក អាន វ៉ាឌី | សមាជិក |
| ២៩ | លោក ខូយ អ៊ាងឡាយ | សមាជិក |
| ៣០ | លោក ឃៀត ផេង | សមាជិក |
| ៣១ | លោក សួ សុខថេង | សមាជិក |
| ៣២ | លោក ឡៅ តុងហាំង | សមាជិក |

❖ **បញ្ជីរាយនាមអគ្គលេខាធិការដ្ឋានសមាគម មាន ៧រូបៈ**

| **ល.រ** | **ឈ្មោះ** | **តួនាទី** |
|---|---|---|
| ១ | ឯកឧត្តម ហ៊ុយ វណ្ណៈ | ទីប្រឹក្សា |
| ២ | បណ្ឌិត តាន់ មុនីវណ្ណ | ទីប្រឹក្សាបច្ចេកទេស |
| ៣ | លោក ហ៊ុយ វណ្ណា | អគ្គលេខាធិការ |
| ៤ | លោកមេធាវី ប៊ុ វណ្ណៈ | ទីប្រឹក្សាច្បាប់ |
| ៥ | លោក គឹម ធារិទ្ធ | ហេរញ្ញិក |
| ៦ | កញ្ញា ប៉ូ សុគន្ធា | រដ្ឋបាល និងលេខាធិការ |
| ៧ | លោក លីម វ៉ាន់ដារ័ត្ន | ជំនួយការទីប្រឹក្សាច្បាប់ |

## IV. ការរៀបចំការិយាល័យ និងប្រព័ន្ធផ្សព្វផ្សាយ

ក្រោមការដឹកនាំរបស់ **លោកឧកញ៉ា លី ហួរ** ជាប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ចាប់តាំងពីបង្កើតសមាគមរហូតមកដល់បច្ចុប្បន្ន លោកឧកញ៉ាបានធ្វើការដឹកនាំ និងមានសកម្មភាពការងារជាច្រើនដែលសមាគមសម្រេចបានដូចតទៅ៖

### 1. ការបង្កើត និងរៀបចំឲ្យមានការិយាល័យសមាគម

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានរៀបចំឲ្យមានការិយាល័យសម្រាប់បុគ្គលិកបម្រើការងារ និងបង្កភាពងាយស្រួលក្នុងការទំនាក់ទំនងការងារជាមួយសមាជិក-សមាជិកា និងសាធារណៈជនផងដែរ ដែលមានអាសយដ្ឋានស្ថិតនៅអគារក្រុមហ៊ុន លី ហួរ គ្រុប (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី) ជាន់ទី៤អាគារលេខ ៨៥-៨៨ មហាវិថី គីមអ៊ីលស៊ុង សង្កាត់បឹងកក់២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ។







### 2. ការធ្វើវិញ្ញាបនបត្រសមាជិក

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានធ្វើវិញ្ញាបនបត្រ ផ្តល់ជូនសមាជិក ចំនួន ៣២ ក្រុមហ៊ុន ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
Housing Development Association of Cambodia

លេខ: ០០១ ស.អ.ល.ក

វិញ្ញាបនបត្រសមាជិក
CERTIFICATE OF MEMBERSHIP

សូមបញ្ជាក់ថា:
ក្រុមហ៊ុន លី ហួរ គ្រុប
ជាសមាជិកនៃសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

This is to certify that :
LY HOUR GROUP
Is a member of The Housing Development Association of Cambodia

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ២០១៦

ប្រធានសមាគម ស.អ.ល.ក

ឧកញ៉ា លី ហួរ

សម្គាល់ : វិញ្ញាបនបត្រនេះមានសុពលភាពត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
Remark: This Certificate is valid until 31 December 2018

3. **ប័ណ្ណសម្គាល់សមាជិក (ID Card)**

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានផលិតប័ណ្ណសម្គាល់សមាជិក (ID Card) ផ្ដល់ជូនសមាជិកចំនួន ៣២ក្រុមហ៊ុន ក្នុងការបង្ហាញពីអត្តសញ្ញាណសម្គាល់ជាសមាជិកសមាគម។

<u>ប័ណ្ណសម្គាល់សមាជិក</u>







4. **បោះពុម្ពនាមប័ណ្ណសម្រាប់សមាជិក (Name Card)**

សមាគមបានធ្វើការបោះពុម្ពនាមប័ណ្ណផ្ដល់ជូន សមាជិក-សមាជិកា ចំនួន ៣២ក្រុមហ៊ុន ដោយនៅផ្នែកម្ខាងនៃនាមប័ណ្ណ បោះពុម្ពក្នុងនាមជាសមាជិក-សមាជិកាសមាគម និងផ្នែកម្ខាងទៀតបោះពុម្ពបង្ហាញពីក្រុមហ៊ុនផ្ទាល់ខ្លួនរបស់សមាជិក-សមាជិកា។

<u>នាមប័ណ្ណសមាជិក</u>




5. **ការបង្កើតគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយ**

a. **ការបង្កើតសៀវភៅទស្សនាវដ្ដី និងវីឌីអូ (Video)**

សមាគមបានចងក្រងសៀវភៅទស្សនាវដ្ដី ដែលមានចំណងជើង សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា និងវីឌីអូ (Video) បង្ហាញពីការវិវត្តនៃវិស័យសំណង់របស់ប្រទេសកម្ពុជា។

រូបគម្របសៀវភៅទស្សនាវដ្តី




b. **ការបង្កើតគេហទំព័រសមាគម** (website)

គេហទំព័រសមាគមគឺ www.hdacambodia.com ឈ្មោះភាសាខ្មែរ **សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា** និងឈ្មោះភាសាអង់គ្លេស Housing Development Association of Cambodia ។

c. **ការបង្កើតបណ្តាញសង្គមសមាគម** Page Facebook

បណ្តាញសង្គមរបស់សមាគមបង្កើតជាភាសាខ្មែរ ដែលមានឈ្មោះ **សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា**

ការបង្កើតគេហទំព័រសមាគម និងប្រព័ន្ធផ្សព្វផ្សាយទាំងនេះ គឺក្នុងគោលបំណង៖

- ក្នុងការផ្សព្វផ្សាយពីសមាគមឲ្យគ្រប់មជ្ឍដ្ឋានស្គាល់យល់ដឹងពីទស្សនៈវិស័យ បេសកកម្ម និងគោលដៅរបស់សមាគម។
- សម្រាប់ជួយផ្សព្វផ្សាយពីគម្រោងអភិវឌ្ឍន៍លំនៅឋានជូនសមាជិក-សមាជិកាសមាគមទាំងអស់។
- ផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពផ្សេងៗ របស់សមាគម និងសកម្មភាពលើវិស័យអចលនវត្ថុ។

រូបភាព Website




រូបភាព Page facebook



## V. សកម្មភាពការងាររបស់សមាគម

**1. ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ កិច្ចប្រជុំផ្ទៃក្នុងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា**

ស្តីអំពី "ការបង្កើតសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា" នៅសណ្ឋាគារកាំបូឌីយ៉ាណា ពិភាក្សាអំពី៖

- ការបង្ហាញគោលបំណងក្នុងការបង្កើត "សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា"។
- ការសម្រេចបង្កើតសមាគម និងរៀបចំឯកសារស្នើសុំទៅក្រសួងជាផ្លូវការ ។





**2. ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៦ កិច្ចប្រជុំ "សន្និបាតវិសាមញ្ញសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា"**

កិច្ចប្រជុំបានធ្វើនៅសណ្ឋាគារកាំបូឌីយ៉ាណា អង្គប្រជុំបានសម្រេច៖

- ការបង្ហាញសមាសភាពថ្នាក់ដឹកនាំសមាគម
- បទបង្ហាញអំពីបេសកកម្មរបស់សមាគម
- មូលដ្ឋានឯកសាររដ្ឋបាលដែលសមាគមសម្រេចបាន
- គម្រោងចំណាយប្រចាំឆ្នាំ
- ការលើកទិសដៅសម្រាប់មហាសន្និបាត
- ការចុះឈ្មោះសមាជិកបាន៣២ ក្រុមហ៊ុន និងប្រមូលប្រាក់ភាគទានសម្រាប់ប្រចាំឆ្នាំ២០១៦។

<u>រូបសកម្មភាពសន្និបាតវិសាមញ្ញសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា</u>









3. **ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦ កិច្ចប្រជុំផ្ទៃក្នុង នៅការិយាល័យសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា៖**

ស្តីពី "ការពិភាក្សាពីបញ្ហាវិស័យអចលនទ្រព្យកម្ពុជា" អង្គប្រជុំបានពិភាក្សា និងសម្រេចលើចំណុចខាងក្រោម៖

- កិច្ចពិភាក្សាលើសេចក្តីណែនាំលេខ០១៤ ចេញថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការធ្វើ របាយការណ៍វឌ្ឍនភាពរបស់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- កិច្ចពិភាក្សាលើសេចក្តីព្រាងប្រកាសថ្មី ចេញថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- កិច្ចពិភាក្សាពីបញ្ហាការអនុវត្តពន្ធលើវិស័យសំណង់ ដោយការបង់ពន្ធរបបស្វ័យប្រកាស (របបពិត)
- ការលើកបញ្ហាផលវិបាកលើការអនុវត្តការបង់ពន្ធរបបស្វ័យប្រកាស (របបពិត) និងស្នើសុំបង់ពន្ធតាមគម្រោងនីមួយៗវិញ។
- ស្នើសុំជួបពិភាក្សាជាមួយ ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ស្តីពីការអនុវត្តពន្ធលើវិស័យអចលនវត្ថុ។
- កិច្ចពិភាក្សាទៅលើបញ្ហាផ្សេងៗលើវិស័យអចលនវត្ថុ និងស្នើសុំជួបសំណេះសំណាលជាមួយអាជ្ញាធរខណ្ឌ និងសាលារាជធានីភ្នំពេញ។





4. **ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ កិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖**

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានដឹកនាំសមាជិក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមាន **ឯកឧត្តម ម៉ី វ៉ាន់** ជាប្រធានអង្គប្រជុំ ដែលពិភាក្សាទៅលើចំណុចមួយចំនួន៖

- ការកំណត់យន្តការរួមគ្នាដោះស្រាយផលប៉ះពាល់ នៃការអភិវឌ្ឍវិស័យសំណង់។
- ការបន្តកិច្ចសហប្រតិបត្តិយ៉ាងជិតស្និទ្ធរវាងវិស័យឯកជន និងសាមីក្រសួងក្នុងការចែករំលែកព័ត៌មានពីវិស័យសំណង់ឲ្យកាន់តែល្អប្រសើរ។
- ការបកស្រាយបន្ថែមលើអត្ថន័យរបស់សេចក្តីព្រាងប្រកាស ស្តីពី "ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន" ដល់សមាជិកសមាគម និងអ្នកអភិវឌ្ឍលំនៅឋាន។
- ក្រសួងស្នើសមាគមធ្វើរបាយការណ៍កែតម្រូវលើសេចក្តីព្រៀងប្រកាស និងផ្ញើសំណើមកក្រសួង
- ក្រសួងនឹងកំណត់ពេលប្រជុំជាមួយសមាគមម្តងទៀត ពិភាក្សាលើប្រការនីមួយៗរបស់សេចក្តីព្រាងប្រកាសនេះ តាមរយៈកិច្ចប្រជុំក្រុមបច្ចេកទេសរបស់សមាគម និងក្រសួងផ្ទាល់។

រូបសកម្មភាពប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ





**5. ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ កិច្ចប្រជុំផ្ទៃក្នុងក្រុមអគ្គលេខាធិការដ្ឋាន៖**

ស្តីពី "ការកែប្រែសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន" នៅការិយាល័យសមាគម ដោយសម្រេច៖

- កែតម្រូវខ្លឹមសារលើចំណុចមួយចំនួននៅក្នុង ជំពូកទី៥ គណនីអភិវឌ្ឍន៍លំនៅឋាន ប្រការ២៩ ជំពូកទី៨ ទោសប្បញ្ញត្តិ
- ធ្វើរបាយការណ៍ស្តីអំពីការកែតម្រូវខ្លឹមសារលើសេចក្តីព្រៀងប្រកាសថ្មីស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅឋានដាក់ជូនលោកឧកញ៉ាប្រធាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។






**6. ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ កិច្ចប្រជុំផ្ទៃក្នុងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា៖**

ស្តីពី "ការពិភាក្សាលើបញ្ហាប្រឈមរបស់សមាជិកលើការអនុវត្តពន្ធ" អង្គប្រជុំបានសម្រេច៖

- ការកំណត់យន្តការពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ អំពីការស្នើសុំពន្យាពេលអនុវត្តបង់ពន្ធតាមរបបស្វ័យប្រកាស(របបពិត)។
- សម្រេចស្នើសុំពន្យាពេលការបង់ពន្ធរបបស្វ័យប្រកាស (របបពិត) និងស្នើសុំអគ្គនាយកដ្ឋានពន្ធដារបង់តាមគម្រោងសំណង់នីមួយៗ។





7. **ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានពន្ធដារៈ**

ស្តីពី "ការស្នើសុំពន្យាពេលអនុវត្តការបង់ពន្ធតាមរបបស្វ័យប្រកាស (របបពិត)" **ឯឧត្តម អេង រតនា** ជាប្រធានអង្គប្រជុំ និងតំណាងឲ្យឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល នៅអគ្គនាយកដ្ឋានពន្ធដារ ការពិភាក្សាលើសកម្មភាព និងលទ្ធផលដូចខាងក្រោម៖

- ការបង្ហាញពីបញ្ហាប្រឈម និងផលវិបាករបស់សមាជិកសមាគមជាអ្នកអភិវឌ្ឍន៍លំនៅឋាន ក្នុងពេលបច្ចុប្បន្ន។
- ការស្នើសុំពន្យាពេលអនុវត្តការបង់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) និងស្នើសុំបង់ពន្ធតាមគម្រោងនៃសំណង់របស់ក្រុមហ៊ុននីមួយៗ ក្នុងកាលៈទេសៈអន្តរកាលនេះ។
- អគ្គនាយកដ្ឋានពន្ធដារបានទទួលសំណើ និងធ្វើរបាយការណ៍ដាក់ជូនទៅថ្នាក់លើដើម្បីឆ្លើយតបសំណូមពររបស់សមាគម នៅពេលបានលទ្ធផលបែបណានោះ នាយកដ្ឋានពន្ធដារ និងអញ្ជើញសមាគមមកពិភាក្សាម្តងទៀត។

<u>រូបសកម្មភាពប្រជុំជាមួយអគ្គនាយកដ្ឋានពន្ធដារ</u>





## VI. ការដោះស្រាយបញ្ហារបស់សមាជិកសមាគម

1. **បញ្ហារបស់ បុរី ធូ លន**

ដោះស្រាយពីបញ្ហា **បុរី ធូ លន** ដែលមានការបង្ហោះព័ត៌មានដែលធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ កិត្តិយសម្ចាស់បុរី **លោកឧកញ៉ា លី ហួរ** ប្រធានសមាគមបានជួយសម្របសម្រួល និងដោះស្រាយបញ្ហា ដោយសម្រេច៖

- ចេញសេចក្តីជូនដំណឹងលេខ ០០១/១៦ សអលក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៦ ប្រកាសជូនសាធារណៈជនតាមរយៈគេហទំព័រ ហ្វ្រេសញូវ (Fresh news) នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៦។
- ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ CNC នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង០៨ ព្រឹក។
- ផ្សព្វផ្សាយលើគេហទំព័រ និងបណ្តាញសង្គមរបស់សមាគម ដើម្បីបញ្ជាក់ពីភាពស្របច្បាប់ និងកុំ ឲ្យមានការយល់ច្រឡំលើក្រុមហ៊ុន **ធូ លន រៀលអ៊ីស្ទេត** បន្តទៀត។

2. **បញ្ហារបស់ ស៊ីណូ ផ្លាស្សាខុនដូ**

សាលាក្រុងរាជធានីភ្នំពេញបានពិន័យប្រាក់ USD24,000 **ស៊ី ណូ ផ្លាស្សាខុនដូ** (ក្រុមហ៊ុន Cambodia Natural Lucky Real Estate Development) លើការបិទផ្ទាំងរូបភាពផ្សព្វផ្សាយពាណិជ្ជកម្មលើរបងហ៊ុមព័ទ្ធការដ្ឋានរបស់ខ្លួន។ លោកឧកញ៉ាប្រធានសមាគមបានដោះស្រាយ និងសម្របសម្រួល ដោយចេញលិខិតស្នើសុំលេខ០០២/១៦ សអលក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ សម្រេចបង់ប្រាក់ត្រឹមចំនួន USD14,000។

## VII. សកម្មភាពការងារសង្គម

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ក្រោមការផ្តួចផ្តើមរបស់លោកឧកញ៉ាប្រធានសមាគម បានធ្វើសកម្មភាពការងារមនុស្សធម៌ជួយដល់សង្គមជាតិ មានដូចជា៖

### 1. ការផ្តល់អំណោយសប្បុរសជូនដល់លោកយាយ កិះ សាអែម

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ក្រុមអគ្គលេខាធិការ ជាតំណាងលោកឧកញ៉ា លី ហួរ និងថ្នាក់ដឹកនាំសមាជិក-សមាជិកាសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានសហការជាមួយអាជ្ញាធរមូលដ្ឋាន នាំយកអំណោយទៅចែកជូនលោកយាយ កិះ សាអែម រស់នៅ ភូមិជើងឃ្លេរ ឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ អំណោយរួមមានទឹកប្រាក់ ៣លាន៣សែនរៀល គ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀតផង។

<u>រូបសកម្មភាពចែកអំណោយ</u>



### 2. អំណោយធ្វើអណ្តូងទឹក (អណ្តូងស្នប់)

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ ក្រោមការស្នើសុំយោបល់របស់លោក ហ៊ុយ វណ្ណា អគ្គលេខាធិការសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា និងមានការឯកភាពពី លោកឧកញ៉ា លី ហួរ ប្រធានសមាគម សម្រេចផ្តល់អំណោយអណ្តូងស្នប់ ចំនួន ១០អណ្តូង ស្មើនឹងទឹកប្រាក់សរុបជិត ២ម៉ឺនដុល្លារអាមេរិក ដល់ខេត្តចំនួន ២៖

- **ខេត្តកំពង់ចាម៖** ឧបត្ថម្ភអណ្តូងស្នប់ចំនួន ៥អណ្តូង សម្រាប់ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម មាន ៣ភូមិ៖ ភូមិវាលគ្រៀល ២ អណ្តូង, ភូមិប៉ែន ២ អណ្តូង និងភូមិត្រពាំងតាសុខ ១ អណ្តូង។
- **ខេត្តពោធិ៍សាត់៖** ឧបត្ថម្ភអណ្តូងស្នប់ចំនួន ៥អណ្តូង សម្រាប់ឃុំក្រពើ ស្រុកវាលវែង មាន ៥ភូមិ ៖ ភូមិក្រពើពីលើ ១ អណ្តូង, ភូមិសំឡាញ ១ អណ្តូង, ភូមិក្រសាំងភ្នៅ ១ អណ្តូង ភូមិកុំប៉ង ១ អណ្តូង និងភូមិអូរចែក ១ អណ្តូង។

<u>រូបភាពអណ្តូងស្នប់ខេត្តកំពង់ចាម</u>



<u>រូបភាពអណ្តូងស្នប់ខេត្តពោធិ៍សាត់</u>



## VIII. ផែនការអនុវត្តបន្ត

សមាគមបានរៀបចំ និងកំណត់ផែនការការងារសម្រាប់អនុវត្តបន្តទៀតរួមមានដូចតទៅៈ

1. ផែនការផ្សព្វផ្សាយពីសមាគមឲ្យគ្រប់មជ្ឈដ្ឋានឲ្យទទួលស្គាល់សមាគមកាន់តែច្រើន ពិសេសអ្នកវិនិយោគលើវិស័យអភិវឌ្ឍន៍លំនៅឋាន។
2. ទាក់ទាញអ្នកវិនិយោគវិស័យអភិវឌ្ឍន៍លំនៅឋាន ឲ្យចូលជាសមាជិកសមាគមឲ្យបានកាន់តែច្រើន
3. នៅបំណាច់ឆ្នាំ២០១៦ ប្រមូលសមាជិកបន្ថែមឲ្យបាន ៤៥ ក្រុមហ៊ុន។
4. ខែសីហា ឆ្នាំ២០១៦ មានផែនការដឹកនាំសមាជិក-សមាជិកាជួបសំណេះសំណាល និងពិភាក្សាការងារលើវិស័យអភិវឌ្ឍន៍លំនៅឋាន ជាមួយអាជ្ញាធរសាលារាជធានីភ្នំពេញ និងអាជ្ញាធរខណ្ឌ។
5. ខែវិច្ឆិកា ឆ្នាំ២០១៦ មានផែនការធ្វើសន្និបាតវិសាមញ្ញសម្រាប់សមាគម។
6. ខែធ្នូ ឆ្នាំ២០១៦ ប្រជុំមហាសន្និបាត និងពិធីជប់លៀង (អញ្ជើញអាជ្ញាធរមានសមត្ថកិច្ចចូលរួមពិភាក្សាអំពីវិស័យអភិវឌ្ឍន៍លំនៅឋាន)។
7. ផែនការពិភាក្សាពីការរៀបចំតាំងពិព័រណ៍វិស័យអចលនវត្ថុកម្ពុជា។

**រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦**

**រៀបចំដោយ**

**អគ្គលេខាធិការ**

**ហ៊ុយ វណ្ណា**

**រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦**

**បានឃើញ និងឯកភាព**

**ប្រធានសមាគម**

**ឧកញ៉ា លី ហួរ**